# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ទិត ចាន់ ភេទ ប្រុស

## រស់នៅភូមិកំពេញចាស់ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

## ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី

## សរុបៈ ១១ទំព័រ

ដារ៉ា : ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ព្រឹកម៉ោង ៩ៈ២៥ ។

ដានី : អ៊ំជីបូនខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ អ៊ំឈ្មោះអីដែរ?

ចាន់ : ខ្ញុំឈ្មោះ ទិត ចាន់ ។

ដានី : ទិត ចាន់?

ចាន់ : បាទ!

ដានី : អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

ចាន់ : ខ្ញុំឆ្នាំច អាយុចិតលើហើយ មិនដឹងចិតប៉ុន្មាន ។

ដារ៉ា : ខ្ទង់ចិត ហើយឆ្នាំចនោះអ៊ំ?

ចាន់ : បាទ!

ដារ៉ា : ឆ្នាំច ខ្ទង់៧០ ។

ចាន់ : ចិតជាងហើយ ។

ដារ៉ា : ចិតជាងអ៊ំនោះ ។

ចាន់ : បាទ!

ដានី : ចុះអ៊ំពេលថ្ងៃនេះអ៊ំរស់នៅក្នុងភូមិ-ឃុំ ស្រុកអីដែរ?

ចាន់ : ពេលថ្ងៃនេះខ្ញុំនៅភូមិកំពេញចាស់ ខ្ញុំមុននៅនោះ ប៉ុនខ្ញុំមកនៅជាមួយក្មួយ ប៉ុន្តែប័ណ្ណគ្រួសារអីផ្ញើនៅក្រុម៦ នៅគមនាគមចាស់ ។

ដានី : អ៊ំពេលថ្ងៃនៅភូមិកំពេញចាស់ ឃុំអីដែរហ្នឹង?

ចាន់ : សង្កាត់ប៉ុន្មាន សង្កាត់៣ ។

ដានី : សង្កាត់៣?

ចាន់ : វាមិនដឹងក្រុងប៉ុន្មានទេ ខ្ញុំមកនៅជាមួយក្មួយ វាក្មេចក្រុមទៀត ។

ដានី : ក្រុងព្រះសីហនុ?

ចាន់ : បាទ!

ដានី : ខេត្តព្រះសីហនុទៀត?

ចាន់ : បាទ!

ដានី : ចុះគ្រួសារអ៊ំ? ប្រពន្ធអ៊ំគាត់ឈ្មោះអី?

ចាន់ : ស្លាប់ ។

ដានី : ស្លាប់?

ចាន់ : ឈ្មោះ សេង សាមុត ។

ដានី : សេង សាមុត គាត់ស្លាប់អីកាលទៅ?

ចាន់ : ស្លាប់៥ឆ្នាំហើយ ។

ដានី អ៊ំមានកូនចៅទេ?

ចាន់ : អត់ តែ២នាក់ប្តីប្រពន្ធ អត់កូន រាល់ថ្ងៃម្នាក់ឯងសុទ្ធ ។

ដានី អ៊ំស្រុកកំណើតកើតជាអ៊ំ នៅណាទៅ?

ចាន់ : នៅភូមិកែវកាំភ្លើង ស្រុកកោះអណ្តែតដែរ ។

ដានី : ភូមិកែកាំភ្លើង?

ចាន់ : បាទ! ភូមិកែវកាំភ្លើង ។

ដានី : ភូមិកែវកាំភ្លើង ។

ចាន់ : ឃុំព្រៃស្វា ស្រុកកោះអណ្តែត ។

ដារ៉ា : ម៉េចបានអ៊ំបានមករស់នៅដល់កំពង់សោម?

ចាន់ : មកតាំងពីក្មេង បេះតែដើរមក ធ្វើការមុនដំបូងនៅភ្នំពេញ ដល់ហើយទទួលអូតែល៧ជាន់ រើសកម្មករសុំមកចូលធ្វើហ្នឹង ធ្វើតាំងពី៦៧ ធ្វើការនៅអូតែលនេះ ៦៧មកដល់៧០គេរដ្ឋប្រហារ ឈប់អស់បុគ្គលិកក្នុងហ្នឹងឈប់អស់រលីង ខ្ញុំក៏ឈប់នឹងគេដែរ រកការងារផ្សេងៗធ្វើ ចិញ្ចឹមខ្លួន ដល់ប៉ុលពតវាវ៉ៃបែកហ្នឹង ជម្លៀសចេញទៅនៅត្រឹមអូរខញ៉ាហេង ។

ដារ៉ា : អីចឹងពេលរដ្ឋប្រហារសម្តេចព្រះនរោត្តមសីហនុហ្នឹង អាអូតែល៧ជាន់ អត់មានដំណើរការទេ មួយអំឡុងពេលរបប លន់ នល់ អីចឹង?

ចាន់ : ដល់របប លន់ នល់ លែងដើរហើយបិទទ្វារចោល នៅកម្មករ៤-៥នាក់ហ្នឹងយាម ។

ដារ៉ា : គ្រាន់តែយាមអីចឹងទេ អត់មានដំណើរការសោះតែម្តង?

ចាន់ : អត់ទេ អត់មានដំណើរការអី រហូត ។

ដារ៉ា : អ៊ឺ! រហូតដល់ ។

ចាន់ : មានភ្ញៀវណាគេមក បើរើគ្នាក្នុងក្តាំង កប៉ាល់ហោះពិបាកឡើង ពិបាកចុះ ។

ដារ៉ា : ហើយរហូតដល់ខ្មែរក្រហមចូល?

ចាន់ : បាទ! ទាល់តែចូល ថ្ងៃខ្មែរក្រហមចូលមកដល់ហ្នឹង គេឲ្យចេញអស់ បានតែ១យប់១ថ្ងៃ គេឲ្យចេញអស់រលីង ប្រគល់សោរ ប្រគល់អីឲ្យគេអស់ ។

ដារ៉ា : អីចឹងនៅក្នុងកំពង់សោមទាំងមូលតែម្តង មានសភាពម៉េចដែរពេលដែលខ្មែរក្រហមចូលមកដល់ដំបូង?

ចាន់ : អត់មានរើសម្ងាប់ អត់ធ្វើបាបអីប្រជាជនទេ គ្រាន់តែមកគេព្រមានថា មិនបាច់យកខោអាវអីច្រើន យកអន្តរអីទៅទេ អង្គការគេចែកឲ្យស៊ីហើយ ទៅតែ២-៣ថ្ងៃមកវិញហើយ នៅនេះខ្លាចអាមេរិកកាំងទំលាក់គ្រាប់បែក ។

ដារ៉ា : និយាយអីចឹង?

ចាន់ : បាទ! និយាយអីចឹង មានអីទៅតែមួយចង្កុះ អាខ្លះទៅអន្តរ២-៣កំប៉ុងហ្នឹងទៅ ចាំអង្គការគេឲ្យមកវិញ មានមកណា ទៅរហូត ទ្រព្យរបស់អីចោលពេញៗផ្ទះ ។

ដារ៉ា : អីចឹងកាលហ្នឹងអ៊ំម្តុំណា ពេល?

ចាន់ : ខ្ញុំនៅជាប់អូតែល៧ជាន់ហ្នឹង នៅអាខាងក្រលុកគេធ្វើផ្ទះរបបប្រេង ឲ្យកម្មករគេនៅ ឥលូវគេរើចោលអស់ហើយ គេធ្វើថ្មីស្អាត ។

ដារ៉ា : អីចឹង ហើយពេលជម្លៀស អ៊ំជម្លៀសចេញតាមភូមិណា ភូមិណាទៅទៀត?

ចាន់ : ទៅតាមថ្នល់ ចេញអីចឹងទៅវែ ទៅឃ្លាំងលើ ទៅខកញ៉ាហេងហ្នឹងនៅហ្នឹងរហូតរហូត ។

ដារ៉ា : ខកញ៉ាហេងហ្នឹងនៅក្នុងភូមិអី ឃុំអីដែរអ៊ំ?

ចាន់ : ស្រុកព្រៃនប់ ។

ដារ៉ា : អូ! នៅក្នុងស្រុកព្រៃនប់ ។ អីចឹងទៅដល់ហ្នឹង អ៊ំទៅជាមួយគ្រួសារអីដែរ?

ចាន់ : បាទ! ទៅជាមួយគ្រួសារខ្ញុំ ។

ដារ៉ា : អីចឹងទៅដល់ខកញ៉ាហេងអីចឹង?

ចាន់ : បាទ! ភូមិខកញ៉ាហេង ។

ដារ៉ា : រស់នៅ?

ចាន់ : គេឲ្យស្នាក់នៅហ្នឹងម៉ង គេថាមិនបាច់ទៅមុខទេ កម្មករយើងអ្នក កម្មករនៅក្រោយហើយ គេឲ្យតែគ្រូៗបង្រៀន ហើយជនជាតិចិនអីទៅមុខ ខ្ញុំកម្មករអីហ្នឹងគេឲ្យនៅក្រោយទៅ ។

ដារ៉ា : វាដឹងច្បាស់ថាអ៊ំធ្វើកម្មករអីចឹង?

ចាន់ : បាទ! វាឆែកមើលឃើញក្រដាសស្នាមយើងនោះ ឃើញកាត យើងពីជំនាន់នោះខ្ញុំប្រើកាត៥ផ្នត់ កាតពីដើម កាតយើងជំនាន់នោះមានរូបថតណា៎ អត់រូបថតទេអាកាត៥ផ្នត់ពីដើម សំបកខ្មៅហើយវែងប៉ុនបាតដៃប្រវែងនេះ កាតពីដើមខ្ញុំគ្នាកាន់បានហ្នឹង ។

ដារ៉ា : អូហ៎!

ចាន់ : គ្មានរូបកាត ។

ដារ៉ា : អត់មានរូបថត?

ចាន់ : គ្មានវៃត្រាត្រង់រូបណាអត់ ។ ដល់នោះដល់ស្ពានទឹកសាបយើងហ្នឹង វាឆែកយកអស់រលីង គ្រាន់តែក្រដាសអេតាស៊ីវិលប្តីប្រពន្ធហ្នឹងក៏វាហូតយកអស់ ថានៅតែខ្លួនទទេគ្មានស្អី ។

ដារ៉ា : ជម្លៀសទៅ ទៅជាមួយអ៊ំស្រីដែរ?

ចាន់ : បាទ!

ដារ៉ា : ចុះទៅកន្លែងភូមិខកញ្ញ៉ាហេង ខ្មែរក្រហមមានបំបែកអ៊ំទេ?

ចាន់ : អត់បំបែកទៅណាទេ គេដាក់ម្តុំៗយើងអ្នកកម្មករ-ស៊ីវិល បើទាហានអីគេប្រើនបញ្ជូនទៅមុខ មិនដឹងក្រោយឯណា ហើយគ្រូបង្រៀន អូហ៎! ពិសេសគ្រូបង្រៀនគេយកទៅដាក់នៅបត់សេមាន់នោះម្តុំ ។

ដារ៉ា : បត់សេមាន់?

ចាន់ : បត់សេមាន់ ។

ដារ៉ា : ហ្នឹងភូមិអី ឃុំអីអ៊ំ?

ចាន់ : ហ្នឹងគេហៅបត់សេមាន់អីចឹង នៅអូរ ហួសពីអូរគោប៉ាំងបន្តិចទៅ ហួសពីខកញ្ញ៉ាហេងទៅនោះទៀត ចុងបញ្ចប់យកគ្នាទៅវៃចោលអស់គ្រូៗ ឲ្យតែដឹងថាគ្រូបង្រៀនមិនដឹងម៉េចយកទៅវៃចោលអស់ ។

ដារ៉ា : វៃចោលម្តុំណាអ៊ំ?

ចាន់ : វៃនៅខាងភ្នំ ខាងក្រោយបត់សេមាន់ហ្នឹង ដឹកឡើងភ្នំយកទៅវៃ ឲ្យតែគ្រូបង្រៀន ។

ដារ៉ា : ហើយចុះអ៊ំពេលទៅដល់ហ្នឹង អង្គការគេឲ្យធ្វើអីទៅ?

ចាន់ : គេឲ្យធ្វើស្រែ ចាំចម្ការ ដាំពោត ដាំស្រូវ ដាំអី នៅធ្វើតែប៉ុណ្ណឹង ។

ដារ៉ា : ជាកង ជាក្រុមអីដែរអ៊ំ?

ចាន់ : បាទ! ដាក់ក្រុមតា៎ ។

ដារ៉ា : ហើយក្នុងកង ក្នុងក្រុមអ៊ំមានពីណាអ្នកដឹកនាំ?

ចាន់ ៖ មានគេសុទ្ធតែអ្នកចាស់ៗ គេពួកអីតំបន់គេចាស់ៗគេកាន់ យើង១៧មានពីណាគេឲ្យកាន់ ធ្វើអី កាន់តែចប កាន់កាំបិតធ្វើស្រែ ។

ដារ៉ា ៖ គេហៅអ្នកមូលដ្ឋានហ្នឹងអីអ៊ឹ?

ចាន់ ៖ បាទ! មូលដ្ឋានហ្នឹង មេកង មេក្រុម យើងអ្នក១៧ យើងអ្នកជម្លៀសចេញពីក្រុងគេហៅ១៧ ។

ដារ៉ា ៖ បាទ! ហើយមានចាំឈ្មោះមេកង មេក្រុមអីដែរ?

ចាន់ ៖ អត់ នៅហ្នឹងគេជម្លៀសពីខេត្តកំពង់ឆ្នាំងមក គេយកមកឲ្យកាន់កង គេកាន់ក្រុម កាន់ដឹកនាំធ្វើការអីៗហ្នឹង ចាំតែឈ្មោះម្នាក់ ឈ្មោះអាប៉ន អាហ្នឹងធ្វើមេកង ឈ្មោះប៉ននៅកំពង់ឆ្នាំង គេជម្លៀសពីហ្នឹងមកឲ្យមកក្តាប់ពួកយើង១៧នៅនេះ ។

ដារ៉ា ៖ ឈ្មោះ ប៉ន?

ចាន់ ៖ បាទ!

ដារ៉ា ៖ នៅកំពង់ឆ្នាំងវិញ?

ចាន់ ៖ បាទ! គេជម្លៀសពីហ្នឹងមក គេយកពួកកំពង់ឆ្នាំងមកក្តាប់ពួកនេះ ។

ដារ៉ា ៖ ជាប្រជាជនធម្មតាយើងដែរ ឬក៏ជាទាហានជាអីពីមុនមក? ឬជាកងទ័ពខ្មែរក្រហម?

ចាន់ ៖ នោះ?

ដារ៉ា ៖ បាទ! ឈ្មោះ ប៉ន ហ្នឹង?

ចាន់ ៖ ភូមិហ្នឹង អធិការភូមិ-ស្រុកដូចយើង ប្រធានសង្កាត់ដូចមេភូមិ មេក្រុមអីចឹង?

ដារ៉ា ៖ អីចឹងគេមកពី?

ចាន់ ៖ បាទ! មកពីហ្នឹងមក ។

ដារ៉ា ៖ ពីកំពង់ឆ្នាំងហ្នឹងមក?

ចាន់ ៖ បាទ! គេបញ្ជូនមកឲ្យក្តាប់ពួកយើង១៧នៅនេះ ។

ដារ៉ា ៖ ក្នុងក្រុមភូមិអ៊ឹហ្នឹង ប្រហែលជាមានប្រជាជនប៉ុន្មាននាក់ទៅនៅហ្នឹង? ហើយសមាសភាពម៉េចដែរអ៊ឹ?

ចាន់ ៖ ភូមិភាគកងខ្ញុំហ្នឹងនៅ៤០០នាក់ ទាំងក្មេង ទាំងចាស់ ទាំងស្រី ទាំងប្រុស ទាំងតូចទាំងធំ ។

ដារ៉ា ៖ ហើយសុទ្ធតែអ្នក១៧មេសា សុទ្ធ ឬក៏យ៉ាងម៉េច?

ចាន់ ៖ បាទ! សុទ្ធតែ១៧ សុទ្ធតែពួកនៅក្រុងហ្នឹងទាំងអស់ ទៅមូល ។

ដារ៉ា ៖ នៅក្រុងកំពង់សោមហ្នឹងម៉ង?

ចាន់ : បាទ!

ដារ៉ា : ហើយក្រោយមកមានបាត់ខ្លួន ឬក៏យ៉ាងម៉េចទេ?

ចាន់ : មានតាំ មានខ្លះ ក្មេងៗជំទង់ៗ អាយុម្ភៃជាង, ២៥អីហ្នឹង ខ្លះចូលទៅកងចល័ត ខ្លះទៅគេមានប្រពន្ធទៅ គេឲ្យធ្វើស្រែធ្វើអី យូរៗជម្លៀសគ្នាយកទៅបាត់ ១-២ៗអីចឹងទៅ ស្ងាត់ៗទៅអត់ដឹងទៅណា ចេះតែអង្គការគេយកទៅជួយកាប់ឈើ យកទៅបាត់រហូត ។

ដារ៉ា : បាត់រហូត?

ចាន់ : បាទ!

ដារ៉ា : អីចឹងអំឡុងពេលរហូតមកដល់៧៩ហ្នឹង ក្នុងភូមិ-ក្រុមអ៊ំនៅសល់ប៉ុន្មានវិញទៅ?

ចាន់ : អត់បានដឹងទេ កាលហ្នឹងគេបំបែកគ្នាអស់ គេដូរៗ ទៅខាងខេត្តកំពង់ឆ្នាំង ទៅសៀមរាប ទៅបាត់ដំបងអី គេជម្លៀស ។

ដារ៉ា : គេបញ្ជូនទៅទៀត?

ចាន់ : គេជម្លៀសពួកយើង១៧ហ្នឹងទៅ ។

ដារ៉ា : ទៅទៀត?

ចាន់ : បាទ! ទៅទៀត ហើយគេយករបស់មូលដ្ឋានចាស់គេយកមកដាក់កន្លែងយើង ហើយខ្ញុំសុំគេទៅដែរ គេមិនឲ្យទៅ នៅហ្នឹងរហូតទៅ ។

ដារ៉ា : អីចឹងអ៊ំនៅកន្លែងភូមិខកញ្ជ៉ាហែងហ្នឹងទាល់តែបែក?

ចាន់ : ទាល់តែថ្ងៃបែក បែកដល់ខែ១០ ៧៩ ខែ១០ហ្នឹង ខ្ញុំមកធ្វើការនៅរោងចក្រប្រេងកាតសុំគេកម្មករនៅហ្នឹង ខាងជាង ។

ដារ៉ា : ខាងជាងអីដែរអ៊ំ?

ចាន់ : ជាងឈើ ។

ដារ៉ា : នៅរោងចក្រប្រេងកាតយើងហ្នឹង?

ចាន់ : បាទ! ខាងមជ្ឈមកាន់កាប់កាលហ្នឹង ។

ដារ៉ា : ខាងមជ្ឈិម?

ចាន់ : បាទ!

ដារ៉ា : ហើយអ៊ំមកដល់ក្នុងខែ១០ ៧៩អីចឹង?

ចាន់ : បាទ! មកដេកបានមួយយប់គេហៅចូលធ្វើការទៅ ។

ដារ៉ា : ហើយអ៊ំមកដល់ខែ១០ ៧៩ហ្នឹង ឃើញស្ថានភាពនៅកំពង់សោមហ្នឹងយ៉ាងម៉េច?

ចាន់ : ស្គាត់ឈឹង មនុស្សមួយៗទេ ក្នុងភូមិហ្នឹងវិញមនុស្សតិច មិនទាន់មានច្រើនទេ មានតែពួកអ្នកធ្វើការដែលមានឈ្មោះយកពីភូមិមកទេ ដល់ប្រជាជនយើងមករកស៊ី សំចតធម្មតាអត់ទាន់មាន មកតែអ្នកធ្វើការ មកកម្មករធ្វើការរដ្ឋអាហ្នឹងមក ដល់ក្រោយៗមកបានចេះតែមានប្រជាជនមកនៅច្រើនៗ តៗគ្នាមក ពីមុនអត់មានទេ មានតែវៀតណាមមកនៅ ហើយយើងអ្នកកម្មករខ្មែរយើងមកបោសជ្រះ ចាប់ធ្វើបញ្ជីក្រសួងអីបង្កើតនេះបង្កើតនោះ ។

ដារ៉ា : អីចឹងអ៊ំចាត់ទុកថា ជាអ្នកដែលចូលមកទីក្រុងកំពង់សោមអាចថាមុនគេដែរ?

ចាន់ : បាទ!

ដារ៉ា : ពីខែ១០ ៧៩មក?

ចាន់ : បាទ!

ដារ៉ា : អីចឹងអ៊ំមកដល់ អ៊ំមានបានដឹងព័ត៌មានពីវត្តឥន្ទញាណទេ?

ចាន់ : អត់ វាគ្មានទាក់ទង គ្មានមនុស្សគ្មានអី មិនដឹងទាក់ទងអ្នកណា សួរអ្នកណាដឹងរឿងអីចេះតែមកថ្មីទាំងអស់គ្នាអីចឹង មកឃើញកន្លែងបន្ទប់ៗអីចឹង ដើរទៅរកអុស រកអីដុតទៅឃើញអីចឹងចេះតែបបួលគ្នា ឆ្ងល់គេធ្វើអី សួរៗយូរៗចេះតែបែក អាហ្នឹងគេធ្វើបន្ទប់ដាក់អ្នកទោស កាលជំនាន់ខ្មែរក្រហម ។

ដារ៉ា : ហើយក្រោយមកអ៊ំមានបានចូលទៅដល់កន្លែងហ្នឹងទេ?

ចាន់ : ខ្ញុំចូលត្រឹមតែមាត់ៗទ្វារ ខ្ញុំបាទ អត់ហ៊ានចូលក្នុង ដើរតែកុដិលោកមួយជួរអីចឹងកំពង់ផែខាងក្រោមអីចឹង ដើរមុខកុដិ យើងមានទៅធ្វើអី ដើរទៅរកអុសរកអីដុត ។

ដារ៉ា : តែអាចជាក្លិន ជាអីដែលអ៊ំ?

ចាន់ : អត់ៗ អត់មានក្លិនទេក្នុងហ្នឹង ស្ងួតបែសឃើញកំទិចកំទី ស្អីកាណោតកាណាត់ អាវកញ្ចាស់ កន្ទេលអីដេក ។

ដារ៉ា : កាល៧៩-៨០អីគេមានធ្វើពិធី ថាគេចុះ៨០, ៨១, ៨២, ៨៣អីហ្នឹងអ៊ំ គេធ្វើជំរឿនអំពីការស្រាវជ្រាវអំពីឧក្រិដ្ឋកម្ម នៃរបបប្រល័យពូជសាសន៍ប៉ុលពតកាលហ្នឹងអ៊ំពេលហ្នឹងអ៊ំមានបានចូលរួម ចូលធ្វើនឹងគេដែរ?

ចាន់ : គេឲ្យធ្វើប្រវត្តិរូបហ្នឹងអី?

ដារ៉ា : បាទ! កាលហ្នឹង ។

ចាន់ : ធ្វើតាំ ខ្ញុំធ្វើឲ្យខាងក្រសួងៗធ្វើយកទៅអស់ហើយ ។

ដារ៉ា ៖ ហើយដល់អីចឹងទៅគេមានការ ដូចថា គាស់រណ្ដៅសាកសពអីចឹង ហើយគេយកឆ្អឹងយកលលាដ៏សាកសព នៃជនរងគ្រោះទៅដម្កល់ទុកអីចឹង អ៊ំមាន?

ចាន់ ៖ អត់អាហ្នឹង ខ្ញុំអត់បានដឹង ។

ដារ៉ា ៖ នៅកំពង់សោមមានទេ?

ចាន់ ៖ នៅកំពង់សោមអត់ដឹងសោះ ។

ដារ៉ា ៖ ចុះរៀងរាល់ថ្ងៃ២០ ឧសភា កាលហ្នឹងគេធ្វើពិធីចងកំហឹងអីនោះ អ៊ំមានដែលចូលរួមដែរ?

ចាន់ ៖ ខ្ញុំអត់បានទៅ គេធ្វើក្នុងក្រុងហ្នឹងតា៎ តែខ្ញុំអត់បានទៅ ។

ដារ៉ា ៖ រៀងរាល់ឆ្នាំតា៎?

ចាន់ ៖ បាទ! គេធ្វើរាល់ឆ្នាំ ។

ដារ៉ា ៖ តែអ៊ំអត់បានទៅរៀងរាល់ឆ្នាំ?

ចាន់ ៖ បាទ! ខ្ញុំអត់បានទៅ ។

ដារ៉ា ៖ ម៉េចអីចឹង?

ចាន់ ៖ ចេះតែរវល់ការងាររហើយយើងចាស់ខ្ជិលទៅអីនឹងគេ ទុកឲ្យក្មេងៗវាទៅ អត់បានទៅនឹងគេ ។ តែក្មេងៗទៅ ចាស់ៗមិនសូវអ្នកណាទៅ ។

ដារ៉ា ៖ អីចឹងអ៊ំមិនបានទៅវត្ត ទៅវ៉ា អីកន្លែងអគ្គតាញាណអី ទៅធ្វើបុណ្យ ធ្វើទានអីទេ?

ចាន់ ៖ អីមិនទៅ ។

ដារ៉ា ៖ កាលពី៧៩ ដំបូងមកមានវត្ត មានវ៉ា អីចាប់ផ្ដើម?

ចាន់ ៖ មានតែវត្ត តែអត់មានលោក លោកទើបមានកើតក្រោយ កាលហ្នឹងមានដំបូងមានបាន២អង្គ ហើយ៣អង្គហ្នឹង ។

ដារ៉ា ៖ ឆ្នាំណាអ៊ំ?

ចាន់ ៖ ៧៩មក មានលោកឈ្មោះ តាអ៊ំៗ លោកមកកសាងវត្តហ្នឹង ឥលូវលោកសុគតបាត់ហើយ លោកសុគត ។

ដារ៉ា ៖ ហើយដំនាន់ លោកតាអ៊ំ ហ្នឹងអ៊ំបានទៅចូលធ្វើបុណ្យ ធ្វើទាននៅវត្តហ្នឹងដែរ?

ចាន់ ៖ ធ្វើតា៎ និមន្តលោកមកសូត្រមន្តផ្ទះ សូត្រអី ។

ដារ៉ា ៖ អត់ទេ ចង់និយាយថាទៅវត្តហ្នឹង ទៅទីតាំងវត្តហ្នឹង?

ចាន់ : ទៅ ប៉ុន្តែខ្ញុំទៅលោកកសាង ពោសប្រាសអីស្អាតអស់ហើយ វាបាត់កន្លែង ទៅកន្លែងបន្ទប់ឃុំឃាំងអីលោករើចោលអស់ លោកធ្វើសារថ្មីឡើងវិញអស់ អាបន្ទប់ឃាំងៗដំបូងកាលខ្ញុំចូលទៅហ្នឹង ថ្ងៃហ្នឹងអត់មានលោក ស្ងាត់ឈឹង សុទ្ធព្រៃណែនវត្តអស់ ។

ដារ៉ា : ចូលទៅឃើញស្ថានភាពម៉េចអ៊ំ?

ចាន់ : ឃើញនៅស្នាមកន្លែងគេដេក កន្លែងស្នាក់នៅហ្នឹង ទៅមើល ពិនិត្យមើលនឹកឃើញថាអើ៎ កន្លែងហ្នឹងមិនមែនកន្លែងយើងដេកធម្មតា មានតែកន្លែងដាក់ទោស ដាក់កញ្ចុក មួយប្រូកៗអីចឹង ។

ដារ៉ា : អ៊ំមានឃើញនៅសល់ស្នាកស្នាមអីផ្សេងទៀត?

ចាន់ : អត់ មានតែឃើញកំទេចកំទីអី សល់ដូចជាខោអាវ ដាច់កណ្តាច ។

ដារ៉ា : ជាស្នាកស្នាមឈាម?

ចាន់ : ស្នាមឈាម ស្នាមអីអត់ ។

ដារ៉ា : អត់ឃើញទេណ៎?

ចាន់ : បាទ! ។

ដារ៉ា : ជាខ្មោះខ្មាង ជាអី ។

ចាន់ : អត់ៗ ។

ដារ៉ា: នៅសេសល់ទេពេលអ៊ំចូលទៅហ្នឹង?

ចាន់ : អត់មានទេ រលីងឈេញ អត់មានឃើញខ្សែ ឃើញដំបង ប្រណាន់អី ។

ដារ៉ា : ក្រោយមកអ៊ំមានដឹងថា មានការគាស់កកាយអី ឆ្អឹង សាកសពជនរងគ្រោះនៅម្តុំហ្នឹងដែរឬក៏?

ចាន់ : អត់ទេ ខ្ញុំអត់ដែលកន្លែងហ្នឹង ខ្លាចខ្មោចសឹងអី អត់ហ៊ានទៅគាស់ខ្មោច ។

ដានី : អ៊ំខ្លាចខ្មោច?

ចាន់ : មិនទៅខ្លាច អីយ៉ះស្មាទោស មិននឹកទៅគាស់រកអីផង ដោយសារតែគេចង់បានមាសបានអី បានគេបេះតែដើរកកូរកកាយ ។

ដានី : ចុះអ៊ំកាលហ្នឹងមានគេទៅគាស់ គេទៅកកូរកកាយ គេទៅអី?

ចាន់ : អាហ្នឹងលឺតាមតៗគ្នា មើលនឹងភ្នែកមិនឃើញ ភ្នែកអត់ឃើញ ខ្លះគេទៅរកគាស់មើលផ្នូរខ្មោចកប់ថ្មីៗ ក្រែងមានមាសមានអី ហើយខ្ញុំអ៊ូ អញមិនចង់បានទេ ។

ដានី : អ្នកភូមិជាមួយអ៊ំហ្នឹងដែលគេទៅគាស់?

ចាន់ : នៅម្តុំផ្សារលើហ្នឹង ពួកចិនៗ ពួកកម្មករដែលរត់ពីក្រោមកហ្នឹង មកនៅជំបូង គេដើររុករើ រកនេះ រកនោះ មិនដឹងជារកអីទេ ខ្ញុំមិនដើរទេ ចូលមកធ្វើការ នៅកន្លែងធ្វើការ មិនដែលទៅខ្វះកកាយរកអីៗ ខ្ញុំមិនរកទេ ។

ដានី : អ៊ីៗមាន ដូចថាដឹង ស្គាល់ពីណាដែលគាត់ចូលកន្លែងវត្តហ្នឹងមុនអ៊ំ? ដូចថាអ៊ំមាន ប្រសាសន៍មិញ ថាពេលអ៊ំចូលទៅគេបោសសំអាតវត្តអស់ហើយ?

ចាន់ : អត់ៗ អត់ស្គាល់មុនជំបូង ចុះទៅមិនដែលជួបមនុស្សអី ជួបអ្នកណាសោះ រួចពីហ្នឹងមកខ្ញុំ ក៏អត់បានទៅវត្តទៅអី ជាប់ការងារយើងខំធ្វើការបម្រើក្រសួងនោះ អត់បានដើរបានអី ។

ដានី : ពេលអ៊ំចូលទៅអីចឹងកន្លែងបន្ទប់ៗអីហ្នឹង កន្លែងខ្នោះ កន្លែងស្នាមអីហ្នឹងអត់មានទេ?

ចាន់ : បាទ! អត់ ឃើញតែបន្ទប់ទទេ ប្រហោងៗ មួយកង់ៗអីចឹង ។

ដានី : វត្តម៉េចដែរ? ដូចឥលូវដែលវត្តហ្នឹង?

ចាន់ : អត់ទេ កខេកកខាកអស់ហើយ ។

ដានី : វត្តកខេក កខាក វត្តយ៉ាងម៉េចទៅអ៊ំនៅចាំទេ?

ចាន់ : វាពុកជញ្ជាំង ពុកទ្វារ បង្អួច ធ្លាក់រញ៉េរញ៉ៃគ្មានអ្នកថែ អ្នកណាបោស សំរាម ស្លឹកឈើ គរណា គរណី វាលតែក្រោមកុដិ កន្លែងវាដាក់អ្នកទោសហ្នឹង ឃើញវាលចន្លោះតិចៗ ។

ដានី : អ៊ំដឹងថាហ្នឹងជាគុករបស់ខ្មែរក្រហម?

ចាន់ : បាទ! ព្រោះមានអ្នកណាមកកាន់កាប់ ពេលលោកជម្លៀសចេញ ខ្ញុំហើយនិងលោកទៅ លោកចេញថ្ងៃជាមួយខ្ញុំដែរ គេដេញចេញ លោកវត្ត ខ្ញុំនៅអូតែលចុះមកជួបជាមួយ លោក ទៅជាមួយគ្នារហូត ។

ដានី : លោកតាអ៊ំហ្នឹង?

ចាន់ : មិនមែនទេ លោកសុគតបាត់ហើយ គេយកទៅសម្លាប់លោកចាលទាំងយប់នោះ ទៅបាន ២-៣ថ្ងៃទៅ លោកគេចាប់លោកផ្សឹក គ្រួសង្ឃរាជនោះ លោកខំ អាត្មាសុំមិនផ្សឹកទេ ប្រើធ្វើអី កាប់ដី កាប់គាស់ ធ្វើស្រែចេះធ្វើបាន ប៉ុន្តែសុំអត់សឹក យប់ឡើងគេយកឡាន មកដាក់ យកទៅបាត់ទៅ សម្លាប់លោកចោលទៅចោរអធិការវត្ត ។

ដានី : តាំងពី៧៥ ជម្លៀសទៅថ្មីៗហ្នឹង?

ចាន់ : បាទ!

ដានី : សម្លាប់ចោលនៅណា?

ចាន់ : នៅម្តុំព្រៃនប់យើងហ្នឹង មិនដឹងនៅច្រកណា មកដឹកយកទៅទាំងយប់ ។

ដានី : ចុះអ៊ីមានដែលលឺគេនិយាយអី ថាគុកហ្នឹងពីណាអ្នកគ្រប់គ្រង? ហើយជាគុកយ៉ាងម៉េច?

ចាន់ : អត់ៗ ដែលលឺ ។

ដានី : អត់ដែលលឺគេនិយាយទេ?

ចាន់ : បាទ! បើមិនបានដើរ បាននិយាយអី យើងមិនមែនអ្នកដើរ ។

ដានី : អត់ដឹងថាគុកហ្នឹងគេចាប់អ្នកមកពីខាងណា ខាងណី មកដាក់កន្លែងហ្នឹង អត់ដែលលឺគេនិយាយទេ?

ចាន់ : អត់ៗ អត់ដែលលឺ ។ ប៉ុន្តែគេគ្រាន់តែនិយាយថា កន្លែងហ្នឹងមានៗ មានដាក់មនុស្សដាក់ឃុំឃាំង ខ្ញុំសង្ស័យតែមនុស្សធ្វើការក្នុងក្រុង អ្នកណាខុសអី ធ្វើអី វាយកដាក់ហ្នឹង ហើយបានគ្នានដឹង មានតែអ្នកធ្វើការខាងកំពង់ផែធ្វើអី នៅក្នុងក្រុងហ្នឹង កាលហ្នឹងវាមានកម្មករខ្មែរយើងអ្នក១៧ហ្នឹង ខ្លះគេយកមកវិញខ្លះ យកមកប្រើ ហើយខ្លាចចាប់ពួកអស់ហ្នឹង ខុសអីទៅគេយកញ្ញុកហ្នឹង ខ្ញុំស្មានទេអាហ្នឹង ។

ដានី : អ៊ីអ្នកដែលគាត់មកនៅ៧៩ មកថ្មីៗដូចអ៊ីដែរ ចាស់ៗសំបុ៉ាល់ៗអ៊ីដែរ នៅក្នុងភូមិយើងមានធនធានដែលទេអ៊ី?

ចាន់ : នៅភូមិនេះខ្ញុំអត់មានទេ ។

ដានី : ដែលគាត់មកនៅភូមិនេះដំបូងគេ នៅក្បែរៗជើងវត្ត ចំណុះជើងវត្តហ្នឹង?

ចាន់ : វាចេញពីនេះទៅនៅស្ទឹងហាវ នៅអីអស់ហើយ បែកគ្នាទៅអស់ហើយ ។

ដានី : ឈ្មោះអីខ្លះទៅអ៊ី អ៊ីស្គាល់ឈ្មោះ នៅចាំឈ្មោះទេ?

ចាន់ : មិនចាំទេ ព្រោះក្រសួងខុសគ្នា គេខាងនេះភូមិនេះកម្មករគេខាងគមនាគមន៍ ហើយខ្ញុំនៅនោះខាងរោងចក្រប្រេងកាត បែកគ្នាអីចឹងបានខ្ញុំអត់ស្គាល់ ។

ដានី : ប៉ុន្តែឥលូវនៅភូមិកំពេញចាស់នេះ អ៊ីមានស្គាល់ពីណាចាស់ៗ ដូចថាសំបុ៉ាល់ៗអ៊ី ក្មេងជាងអ៊ីបន្តិចបន្តួចអី ហើយគាត់អ្នកចាស់រស់នៅហ្នឹងយូរហើយ តាំងពី៧៩មក? មានស្គាល់ទៀតទេ?

ចាន់ : មានតា តែខ្ញុំស្គាល់គាត់ទើបខ្ញុំមកនៅនេះដែរ តាមួយនៅក្រោយ ឈ្មោះ តាលេនៗ ។

ដានី : ឈ្មោះតាអី?

ចាន់ : កុង លេន ។

ដានី : គង់ លេន ។ ផ្ទះគាត់នៅណាទៅ?

ចាន់ : ទៅផ្លូវបត់បេះមក នៅទល់ក្រោយដីឡូហ្នឹង ។

ដានី :	សួរគេ ឈ្មោះ តាលេនៗ អីចឹងគេស្គាល់ហើយ?

ចាន់ :	បាទ! បាទ!

ដានី :	គាត់មានប្រពន្ធ ប្រពន្ធគាត់ឈ្មោះអីទៅ?

ចាន់ :	ប្រពន្ធអត់ស្គាល់ឈ្មោះ ស្គាល់តែគាត់ កូនច្រើនណាស់តាហ្នឹង កូនចៅគាត់នៅមួយកំផ្លុស ។

ដានី :	ឥលូវគាត់នៅផ្ទះដែរ?

ចាន់ :	នៅតា៎ ។

ដានី :	អីចឹងយើងជិះចេញតាមហ្នឹងទៅ បត់មកចេះវិញ?

ចាន់ :	បាទ! ចេញអីចឹងទៅ ចេញអីចឹងមក មានអាកូនផ្លូវមួយតូចត្រង់ឡើង នេះមុខដីឡូទល់គ្នាផ្លូវ ផ្ទះហ្នឹង ផ្លូវកណ្ដាល ផ្ទះគាត់ចូលមកនៅស្ដាំដៃ ។

ដានី :	បាទ! អីចឹងអ៊ុំខ្ញុំអរគុណអ៊ុំច្រើន ដែលអ៊ុំបានចំណាយពេលផ្ដល់ព័ត៌មានឲ្យពួកខ្ញុំ ទាក់ទងរឿងវត្តឥន្ទញាណ ។

ចាន់ :	ខ្ញុំមិនបានដើរទៅអី បានអត់ដឹង .... មិនដើររហេតរហូតអីខំធ្វើការកាលហ្នឹង ។

ដានី :	បាទ! ខ្ញុំអរគុណច្រើនអ៊ុំ ។

ចាន់ :	បាទ! ជិះព្រលឹមឡើងឲ្យឃើញវត្ត មិនហ៊ានចុះ ។

**ចប់**